**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
******

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
******

# ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ទទួលលោកជំទាវ ធាវ ឡេ ឈិង ឯកអគ្គរដ្ឋទូតថ្មីនៃសាធារណរដ្ឋសិង្ហបុរី ប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម

******

នៅព្រឹកថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឲ្យលោកជំទាវ **ធាវ ឡេ ឈិង** (Teo Lay Cheng) ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋសិង្ហបុរី ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះលោកជំទាវឯកអគ្គរដ្ឋទូតដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតថ្មី នៃសាធារណរដ្ឋសិង្ហបុរី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។ **ឯកឧត្តម** បានរំពឹងទុកថា ទំនាក់ទំនងដ៏ល្អដែលមានស្រាប់រវាងកម្ពុជា និងសិង្ហបុរី រួមទាំងកិច្ចសហប្រតិបត្តិការនៅលើគ្រប់វិស័យ នឹងត្រូវបានពង្រីកនិងធ្វើឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត នៅក្នុងអាណត្តិរបស់លោកជំទាវ។ **ឯកឧត្តម** ក៏បានបញ្ជាក់អំពីការត្រៀមផ្តល់កិច្ចសហការពេញលេញរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដល់លោកជំទាវក្នុងការបំពេញបេសកកម្មឱ្យទទួលបានជោគជ័យនៅកម្ពុជា។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា តាមរយៈទំនាក់ទំនងដ៏ល្អរវាងថ្នាក់ដឹកនាំជាន់ខ្ពស់នៃប្រទេសទាំងពីរ និងកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធនៅលើគ្រប់វិស័យ រួមមាន អប់រំ ពាណិជ្ជកម្ម វិនិយោគ និងការផ្លាស់ប្តូររវាងប្រជាជននិងប្រជាជន បានជួយពូនជ្រុំទំនាក់ទំនងទ្វេភាគីឱ្យកាន់តែល្អប្រសើរឡើងជាដរាប។ **ឯកឧត្តម** បានរំលឹកផងដែរ ឆ្នាំ២០២០ កន្លងមកនេះ គឺជាខួបលើកទី៥៥ នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសកម្ពុជានិងសិង្ហបុរី ដែលនៅពេលនោះ កម្ពុជា និងសិង្ហបុរីបានរៀបចំកម្មវិធី និងព្រឹត្តិការណ៍ជាច្រើន រួមទាំងព្រឹត្តិការណ៍ Street Art Fest++ ផងដែរ។ **ឯកឧត្តម** ក៏បានរំលឹកអំពីទំនាក់ទំនងជាប្រវត្តិសាស្ត្ររវាងកម្ពុជា និងសិង្ហបុរី ដែលក្នុងឆ្នាំ១៩៦៥ កម្ពុជាគឺជាប្រទេសមួយក្នុងចំណោមបណ្តាប្រទេសដំបូងគេ ដែលបានប្រកាសទទួលស្គាល់ឯករាជ្យភាពរបស់ប្រទេសសិង្ហបុរី ហើយប្រទេសទាំងពីរក៏បានភ្ជាប់ទំនាក់ទំនងការទូតជាផ្លូវការ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៦៥។

ជាការឆ្លើយតប **លោកជំទាវឯកអគ្គរដ្ឋទូត** បានមានប្រសាសន៍ថា លោកជំទាវមានកិត្តិយស និងសេចក្តីសោមនស្សរីករាយ ដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំកម្ពុជា ហើយ **លោកជំទាវ** នឹងខិតខំបន្តលើកកម្ពស់ និងពង្រីកបន្ថែមទៀតនូវទំនាក់ទំនងដ៏ល្អដែលមានស្រាប់រវាងប្រទេសទាំងពីរ និង

ធ្វើឱ្យកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ បានប្រកបដោយផ្លែផ្កា ជាពិសេស វិស័យអប់រំ សេដ្ឋកិច្ច ពាណិជ្ជកម្ម និង វិនិយោគ។ លោកជំទាវ ក៏បានថ្លែងអំណរគុណជាពិសេស ជូនចំពោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ដែលបានទទួលសវនាការរបស់លោកជំទាវនៅក្នុងពេលវេលានេះ។

ក្នុងឱកាសនោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានកោតសរសើរដល់រដ្ឋាភិបាលសិង្ហបុរី ដែលបានដាក់ចេញនូវវិធានការណ៍ដ៏មានប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩។ **ឯកឧត្តម** ក៏បានជម្រាបជូនលោកជំទាវផងដែរថា រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវកម្មវិធីចាក់វ៉ាក់សាំងជំងឺកូវីដ-១៩ ដោយឥតគិតថ្លៃ និងតាមគោលការណ៍ស្ម័គ្រចិត្ត ជូនអ្នកការទូតបរទេស និងក្រុមគ្រួសារ និងបុគ្គលិកបរទេសនៃអង្គការអន្តរជាតិនិងក្រុមគ្រួសារ ដែលកំពុងបំពេញភារកិច្ច និងស្នាក់នៅក្នុងប្រទេសកម្ពុជា។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងចាក់វ៉ាកសាំងជំងឺកូវីដ-១៩ ជូនដល់ប្រជាពលរដ្ឋកម្ពុជា ដោយស្ម័គ្រចិត្ត និងឥតគិតថ្លៃ ផងដែរ ។

**ភាគីទាំងពីរ**បានកត់សម្គាល់ដោយពេញចិត្តថា បើទោះបីនៅក្នុងបរិការណ៍នៃជំងឺរាតត្បាតសកលកូវីដ-១៩ក្តី ទំហំពាណិជ្ជកម្មទ្វេភាគី និងទំហំវិនិយោគរបស់សិង្ហបុរីនៅកម្ពុជា មានការកើនឡើងជាបន្តបន្ទាប់។ ជាក់ស្តែង ទំហំពាណិជ្ជកម្មទ្វេភាគីបានកើនឡើងរហូតដល់ប្រមាណបួនពាន់លានដុល្លារ នៅក្នុងឆ្នាំ២០២០។ ចំណែកឯទំហំនៃការវិនិយោគក៏បានកើនដល់ ៤៨លានដុល្លារ នៅក្នុង៩ខែដើមឆ្នាំ២០២០ ផងដែរ។ ភាគីទាំងពីរយល់ស្របគ្នាថា កម្ពុជា និងសិង្ហបុរី នៅមានសក្តានុពលសំខាន់ៗជាច្រើនទៀត ដើម្បីជម្រុញ និងលើកកម្ពស់វិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគទ្វេភាគីឱ្យមានទំហំកើនឡើងខ្ពស់ថែមទៀត។

សម្រាប់កិច្ចសហប្រតិបត្តិការលើឆាកអន្តរជាតិ **ភាគីទាំងពីរ**បានឯកភាពបន្តកិច្ចសហការគ្នាយ៉ាងជិតស្និទ្ធ និងគាំទ្រគ្នាទៅវិញទៅមកនៅលើឆាកអន្តរជាតិ ដើម្បីផលប្រយោជន៍ទៅវិញទៅមក។ សូមបញ្ជាក់ថា សិង្ហបុរីបានគាំទ្រដល់កម្ពុជា ក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី១៣ (The ASEM13) ក្នុងឆ្នាំ២០២១ នេះ ហើយកម្ពុជាសង្ឃឹមជឿជាក់ថា សិង្ហបុរី នឹងបន្តគាំទ្រយ៉ាងពេញលេញនៅពេលកម្ពុជាទទួលវេនធ្វើជាប្រធានអាស៊ានក្នុងឆ្នាំ២០២២ ខាងមុខនេះផងដែរ។

ក្រៅពីនេះ **ភាគីទាំងពីរ**ក៏បានផ្លាស់ប្តូរយោបល់គ្នាលើបញ្ហាដែលកំពុងកើតឡើងនៅក្នុងតំបន់ និងអន្តរជាតិ ដែលជាការយកចិត្តទុកដាក់រួម ផងដែរ៕

-----------------------------